# 45 호미를 챙겼는데요

## ខ្ញុំបានត្រៀមប្រដាប់កាយដំឡូង

**학습 안내**
ការណែនាំអំពីមេរៀន

| | |
|---|---|
| □ វត្ថុបំណងមេរៀន | ការទាមទារឲ្យមានការផ្លាស់ប្តូរការងារ, ការស្នើរសុំការងារ |
| □ វេយ្យាករណ៍ | -는데요, -기 전에 |
| □ ពាក្យថ្មី | វិស័យកសិកម្ម ១, វិស័យកសិកម្ម ២ |
| □ ព័ត៌មាន · វប្បធម៌ | រដូវកាលទាំងបួននៃជនបទ(ស្រុកស្រែចម្ការ)ប្រទេសកូរ៉េ |

## 대화 1 ការសន្ទនា ១

Track 139



លីលីកំពុងតែជជែកលេងជាមួយនឹងមីងម្ចាស់កសិដ្ឋាន។ ជាដំបូង សូមស្តាប់ការសន្ទនាឲ្យបាន២ដង រួចហើយចូរថាតាម។

**주인 아주머니** 리리 씨, 괭이 챙겼어요?
លីលី! តើមានបានត្រៀមចបកាប់ហើយឬនៅ?

**리 리** 괭이요? 오늘 고구마 캐는 일을 하신다고 해서 호미를 챙겼는데요.
ចបកាប់? ដោយសារតែខ្ញុំលឺថាថ្ងៃនេះគឺធ្វើការ(ជីក)កាយដំឡូងជ្វា ទើបខ្ញុំបានត្រៀមប្រដាប់កាយដំឡូងមក។

**주인 아주머니** 오늘 일할 밭은 너무 딱딱해서 호미로 하기 힘들어요. 그리고 괭이로 고구마를 캘 때는 호미로 할 때보다 고구마에 상처가 나기 쉬우니까 조심해야 돼요.
ដោយសារតែច្បារដំណាំដែលយើងនឹងធ្វើការ ដីមានសភាពរឹងខ្លាំង ដូច្នេះបើប្រើប្រដាប់កាយធ្វើ គឺលំបាក។ ហើយនៅពេលដែលធ្វើការជីកដំឡូងដោយប្រើចបកាប់ គឺងាយនឹងធ្វើឲ្យដំឡូងមានស្នាមឆ្កូតជាងពេលប្រើប្រដាប់កាយ ដូច្នេះអ្នកត្រូវតែប្រុងប្រយ័ត្ន។

**리 리** 그렇군요. 그럼 창고에 가서 얼른 가지고 올게요.
បែបនេះសោះ, អញ្ចឹងខ្ញុំនឹងទៅឃ្លាំង ហើយប្រញាប់យកមកភ្លាម។

**챙기다** ត្រៀម(យក/មើលថែរក្សា)
- 시험을 보러 갈 때에는 신분증을 챙겨야 해요.
  នៅពេលដែលអ្នកទៅប្រលងអ្នកត្រូវតែយក(ត្រៀម)អត្តសញ្ញាណប័ណ្ណទៅ។
- 부모님이 집에 안 계시면 제가 동생들을 챙깁니다.
  ប្រសិនបើឪពុកម្តាយមិននៅ គឺខ្ញុំជាអ្នកមើលថែប្អូនៗ។

**얼른** ជាបន្ទាន់/ ឲ្យលឿន/ប្រញាប់/ ភ្លាមៗ
- 라면은 식기 전에 얼른 먹어야 맛있어요.
  មុនពេលមីត្រជាក់ ត្រូវប្រញាប់ញ៉ាំឲ្យលឿនទើបឆ្ងាញ់។
- 시험을 볼 때에는 한국어가 얼른 생각이 나지 않아요.
  នៅពេលប្រលង ខ្ញុំនឹកមិនឃើញពីភាសាកូរ៉េបានភ្លាមៗនោះទេ។



តើអ្នកបានស្តាប់ រួចថាតាមហើយមែនទេ? បើអញ្ចឹង សូមធ្វើការឆ្លើយសំណួរខាងក្រោម។

1. 리리 씨는 오늘 무슨 일을 할 거예요? តើថ្ងៃនេះលីលីនឹងធ្វើអ្វី?
2. 리리 씨는 왜 창고에 가려고 해요? តើហេតុអ្វីបានជាលីលីមានបំណងចង់ទៅឃ្លាំង?

**정답** 1. 고구마 캐는 일을 할 거예요. 2. 괭이를 가지러 창고에 가려고 해요.

## 어휘 1 ពាក្យថ្មី ១ | 농업 1 វិស័យកសិកម្ម ១

តោះ! យើងមើលពាក្យ ក៏ដូចជាកន្សោមពាក្យដែលពាក់ព័ន្ធទៅនឹងវិស័យកសិកម្មថាមានអ្វីខ្លះទាំងអស់គ្នា។


논
ស្រែ


밭
ច្បារដំណាំ


농장
កសិដ្ឋាន


과수원
ចំការផ្លែឈើ


비닐하우스
រោងដាំដំណាំគ្របប្លាស្ទិក


낫
កណ្ដៀវ


호미
ប្រដាប់កាយដំឡូង


괭이
ចបកាប់


곡괭이
ត្រសេះ


삽
ប៉ែល


모종삽
កូនប៉ែលដាំដំណាំ


갈퀴
រនាស់


쇠스랑
សមចូកសំរាម


호스
ទុយោ


물뿌리개
ធុងស្រោចទឹក


파종 상자
កញ្ច្រែងបណ្ដុះគ្រាប់ពូជ


농약 분무기
ធុងបាញ់ថ្នាំកសិកម្ម


경운기
គោយន្ត


콤바인
ម៉ាស៊ីនច្រូតកាត់ និងបោកបែន

សូមឆ្លើយសំណួរ ដោយកុំមើលពាក្យខាងលើ។

1. 사진을 보고 알맞은 말을 연결하세요. សូមមើលរូបភាព បន្ទាប់មកចូរភ្ជាប់ទៅនឹងពាក្យដែលត្រឹមត្រូវ។

① 
② 
③ 
④ 
⑤ 

㉠ 모종삽 ㉡ 쇠스랑 ㉢ 경운기 ㉣ 갈퀴 ㉤ 낫

정답 ① ㉤ ② ㉠ ③ ㉣ ④ ㉡ ⑤ ㉢

## 문법 1 វេយ្យាករណ៍ ១ | -는데요

G45-1

យើងប្រើប្រាស់វាភ្ជាប់ជាមួយកិរិយាស័ព្ទ ដើម្បីបង្ហាញអំពីការពិពណ៌នាអំពីស្ថានការណ៍ឬក៏ព័ត៌មានអ្វីមួយ។ ទោះបីជាកិរិយាស័ព្ទមានជើងឬក៏គ្មានជើងក៏ដោយ គឺយើងប្រើប្រាស់ជាទម្រង់ '-는데요' ទាំងអស់។

| 동사(កិរិយាស័ព្ទ) | 형용사(គុណនាម) | | 명사(នាម) |
|---|---|---|---|
| **-는데요** | 자음(ព្យញ្ជនៈ) → **-은데요** | 모음(ស្រៈ) → **-ㄴ데요** | **인데요** |
| 먹다 → 먹**는데요**<br>오다 → 오**는데요** | 많다 → 많**은데요** | 크다 → **큰데요** | 사람 → 사람**인데요**<br>친구 → 친구**인데요** |

- 농약을 쳐야 **하는데요**. 농약 분무기가 어디에 있는지 모르겠어요.
  ត្រូវតែបាញ់ថ្នាំសម្លាប់សត្វល្អិត។ ខ្ញុំមិនដឹងថាធុងបាញ់ថ្នាំគឺមីនៅឯណានោះទេ។
- 가: 사과 상자들을 트럭에 다 **실었는데요**. 좀 봐 주세요.
  ខ្ញុំបានដាក់កេសផ្លែប៉ោមទាំងឡាយចូលទៅក្នុងឡានរួចរាល់ហើយ។ សូមជួយឆែកមើលផង។
  나: 그래요. 잠깐만 기다리세요. អូខេ! សូមរង់ចាំបន្តិច។

### 비교해 보세요 សូមសាកល្បងធ្វើការប្រៀបធៀប

**✔ រវាង '-는데요' និង '-는데'**

គឺមានន័យដូចគ្នា។ គ្រាន់តែនៅពេលដែលបន្ថែម '요' វាដើរតួនាទីក្នុងការបញ្ចប់ប្រយោគ បើគ្មានវាទេ គឺភ្ជាប់ប្រយោគចូលជាប្រយោគតែមួយវិញ។

- 밖에 비가 많이 **오는데요**. 창문을 닫을까요? នៅខាងក្រៅភ្លៀងធ្លាក់ខ្លាំងណាស់។ បិទបង្អួច ឬក៏យ៉ាងណា?
- 모니카 씨, 날씨도 **좋은데** 우리 오늘 놀러 갈까요?
  កញ្ញា ម៉ូនីខា! ថ្ងៃនេះ អាកាសធាតុល្អ ពួកយើងចេញទៅដើរលេងយ៉ាងម៉េចដែរ?
- 이 음식이 **불고기인데요**. 정말 맛있어요. ម្ហូបនេះ គឺភ្លូលកូគី។ ពិតជាឆ្ងាញ់ណាស់។



តើអ្នកយល់ពី '-는데요' ហើយឬនៅ? បើអញ្ចឹង សូមសាកល្បងបញ្ចប់ការសន្ទនា ដោយធ្វើការបំពេញល្បះឲ្យបានត្រឹមត្រូវ។

2. '-는데요'를 사용해서 대화를 완성하세요. សូមបំពេញការសន្ទនាដោយប្រើប្រាស់ '-는데요'។

1) 가: ______________________. 괭이 어디 있어요? [고구마를 캐야 하다 ត្រូវ(ជីក)កាយដំឡូងជ្វា]
   나: 아까 제가 쓰고 창고에 뒀어요. អំបាញ់មិញ ខ្ញុំប្រើហើយ ខ្ញុំបានយកទៅដាក់នៅក្នុងឃ្លាំងហើយ។

2) 가: ______________________. 호스가 없네요. [물을 줘야 하다 ត្រូវដាក់ទឹក]
   나: 제가 찾아 줄게요. ចាំខ្ញុំទៅរកយកមកឲ្យ។

3) 가: ______________________. 같이 할 수 있어요? [파종상자를 옮겨야 하다 ត្រូវផ្លាស់ទី ប្រអប់សាបព្រួស]
   나: 그럼요. 같이 해요. ប្រាកដហើយ! ធ្វើជាមួយគ្នាទៅ។

정답 1) 고구마를 캐야 하는데요 2) 물을 줘야 하는데요 3) 파종상자를 옮겨야 하는데요

## 대화 2 ការសន្ទនា ២

Track 140

កញ្ញា លីលី កំពុងតែជជែកលេងជាមួយនិងមីងម្ចាស់កសិដ្ឋាន។ សូមស្ដាប់ការសន្ទនាឲ្យបាន ២ ដង ហើយថាតាម។

**주인 아주머니** 오늘 고생 많았어요. 내일은 밭에 비료를 뿌릴 거니까 준비 좀 해 줘요.
ថ្ងៃនេះ ហត់នឿយហើយ។ ថ្ងៃស្អែកយើងនឹងធ្វើការបាចជីគីមី ដូច្នេះ សូមត្រៀមទុកឲ្យផង។

**리 리** 비료요? 모종은 다음 주에 심을 건데 벌써 비료를 뿌려요?
ជី? ក្រែងកូនឈើសប្ដាហ៍ក្រោយទើបយើងដាំ តែយើងបាចជីគីមីពីឥឡូវទៅហើយ?

**주인 아주머니** 모종을 심기 전에 뿌려야 돼요. 비료를 먼저 뿌리고 일주일쯤 지난 후에 심어야 모종이 잘 자라거든요.
មុនពេលដាំកូនឈើ គឺត្រូវតែបាចជីទុកមុន។ ពីព្រោះថាពេលយើងបាចជីគីមីទុកជាមុនហើយមួយសប្ដាហ៍ក្រោយទើបដាំ កូនឈើ វានឹងអាចលូតលាស់បានល្អ។

**리 리** 아, 그렇군요. 제가 들어가서 내일 쓸 비료 잘 챙겨 놓을게요.
អូ! អញ្ចឹងសោះ។ ចាំខ្ញុំចូលទៅខាងក្នុង ដើម្បីត្រៀមជីគីមីដែលត្រូវប្រើនៅថ្ងៃស្អែក។

> **벌써** រួចរាល់(ហើយ/បាត់)
> - 벌써 금요일이에요.
>   ថ្ងៃសុក្របាត់។
> - 회의 준비를 벌써 다 했어요?
>   តើអ្នកបានរៀបចំការប្រជុំរួចរាល់អស់ហើយឬ?

> **쯤** ប្រហែល/ខ្ទង់
> - 일주일쯤 후에 다시 연락을 주세요.
>   ប្រហែលជាមួយអាទិត្យក្រោយ សូមទាក់ទងមកម្ដងទៀត។
> - 내일 2시쯤 만날까요?
>   ថ្ងៃស្អែកយើងជួបគ្នាខ្ទង់ម៉ោង ២ យ៉ាងម៉េចដែរ?

តើអ្នកបានស្ដាប់និងថាតាមហើយមែនទេ? បើអញ្ចឹង សូមសាកល្បងឆ្លើយសំណួរខាងក្រោម។

1. 언제 비료를 뿌리려고 해요? តើមានបំណងចង់បាចជីនៅពេលណាដែរ?
2. 모종은 언제 심으려고 해요? តើមានបំណងចង់ដាំកូនឈើនៅពេលណាដែរ?

**정답** 1. 내일 뿌리려고 해요. 2. 다음 주에 심으려고 해요.

### Tip 곡류 ប្រភេទគ្រាប់ធញ្ញជាតិ


벼 ស្រូវ


보리 ស្រូវបាឡេ


밀 ស្រូវសាលី


콩 សណ្ដែក

## 어휘 2 ពាក្យថ្មី ២ | 농업 2 វិស័យកសិកម្ម ២



តើពាក្យ ក៏ដូចជាកន្សោមពាក្យដែលពាក់ព័ន្ធទៅនឹងវិស័យកសិកម្មមានអ្វីខ្លះ?
តោះ! យើងមើលទាំងអស់គ្នា។



키우다/기르다/재배하다
ដាំដុះ



거두다/수확하다
ប្រមូលផល



따다
បេះ



캐다
កាយ, គាស់, ជីក, រាវ



비료를 뿌리다
បាចជីគីមី



씨앗을 뿌리다
ព្រួស ឬសាបគ្រាប់ពូជ



모종을 심다
ដាំកូនឈើ



물을 주다
ស្រោចទឹក



거름을 주다
ដាក់ជី



잡초를 뽑다
ដកស្មៅ



벌레를 잡다
ចាប់សត្វល្អិត



농약을 치다
បាញ់ថ្នាំ(កសិកម្ម)



សូមឆ្លើយសំណួរ ដោយកុំមើលពាក្យខាងលើ។

2. 그림에 맞는 표현을 〈보기〉에서 골라 넣으세요.
សូមជ្រើសរើសកន្សោមពាក្យដែលត្រឹមត្រូវមាននៅក្នុងឧទាហរណ៍ បំពេញទៅតាមរូបភាព។



1) ______ →



2) ______ →



3) ______ →



4) ______ →



5) ______

**보기**
씨앗을 뿌리다 거름을 주다 캐다
물을 주다 잡초를 뽑다

**정답** 1) 씨앗을 뿌리다 2) 물을 주다 3) 거름을 주다 4) 잡초를 뽑다 5) 캐다

## 문법 2 វេយ្យាករណ៍ ២ | -기 전에

G45-2

'-기 전에' គឺប្រើប្រាស់ជាមួយនឹងកិរិយាស័ព្ទ សម្រាប់ពិពណ៌នាពីការកើតឡើងនៃសកម្មភាពខាងក្រោយដែលកើតឡើងមុនសកម្មភាពដែលនៅខាងមុខ។ មិនថាកិរិយាស័ព្ទមាន ផាត់ឈឹម ឬក៏គ្មាននោះទេ គឺគ្រាន់តែបូកជាមួយនឹង '-기 전에' ជាការស្រេច។

- 비닐을 **덮기 전에** 거름을 먼저 주세요. មុនពេលគ្របប្លាស្ទិក សូមធ្វើការដាក់ជីជាមុនសិន។
- 가: 한국에 **오기 전에** 방글라데시에서 무슨 일을 했어요? មុនពេលអ្នកមកប្រទេសកូរ៉េ តើអ្នកបានធ្វើការងារអ្វី?
  나: 무역 회사에 다녔어요. ខ្ញុំធ្លាប់បានធ្វើការនៅក្រុមហ៊ុនពាណិជ្ជកម្ម។

### 비교해 보세요 សូមសាកល្បងធ្វើការប្រៀបធៀប

**✔ រវាង '-기 전에' និង '-(으)ㄴ 후에'**

'-기 전에' គឺប្រើសម្រាប់ពិពណ៌នាពីការកើតឡើងនៃសកម្មភាពឬរឿងហេតុដែលនៅខាងក្រោយ កើតមុនសកម្មភាពដែលនៅខាងមុខ ចំណែកឯ '-(으)ㄴ 후에' វិញ គឺប្រើដើម្បីបង្ហាញអំពីសកម្មភាពដែលនៅខាងមុខ កើតឡើងមុនសកម្មភាពដែលនៅពីខាងក្រោយវា។

- 모종을 **심기 전에** 비료를 뿌려요. មុនពេលដាំកូនឈើ បាចជីជាមុន។
- 비료를 **뿌린 후에** 모종을 심어요. បន្ទាប់ពីបាចជីហើយ ដាំកូនឈើ។



តើអ្នកយល់ពីការប្រើប្រាស់ '-기 전에' ហើយមែនទេ? សូមធ្វើការសរសេរឃ្លា/កន្សោមពាក្យដែលត្រឹមត្រូវ ហើយសាកល្បងបំពេញការសន្ទនា។

2. 그림을 보고 '-기 전에'를 사용해서 대화를 완성하세요.
   សូមមើលរូបភាព បន្ទាប់មកចូរប្រើប្រាស់ '-기 전에' មកបញ្ចប់ការសន្ទនា។

1) 

가: 토마토를 딸까요? តើគួរបេះផ្លែប៉េងប៉ោះដែរឬទេ?
나: 아니요, ______________________.

2) 

가: 물을 줄까요? តើគួរស្រោចទឹកដែរឬទេ?
나: 아니요, ______________________.

정답 1) 토마토를 따기 전에 농약을 치세요 2) 물을 주기 전에 잡초를 뽑으세요

### 유용한 표현 កន្សោមពាក្យសំខាន់ៗ

**익숙해졌어요.** ទម្លាប់(ស្ទាត់/ជំនាញ/ស៊ាំ)ហើយ។

가: 한국에서 생활하는 게 힘들지요? តើការរស់នៅក្នុងប្រទេសកូរ៉េ លំបាកត្រូវទេ?
나: 처음에는 힘들었는데 **이제 익숙해졌어요.** កាលពីដំបូងគឺរាងលំបាក ក៏ប៉ុន្តែឥឡូវនេះខ្ញុំរាងស៊ាំ(បន្តិច)ហើយ។

## 활동 សកម្មភាព

작업을 요구할 때는 어떻게 이야기해야 할까요? 〈보기〉처럼 말해 보세요.
តើនៅពេលដែលអ្នកចង់ធ្វើការទាមទារ(ត្រូវការ)អ្វីមួយ តើអ្នកគួរតែនិយាយបែបណា?
សូមសាកល្បងនិយាយដូចទៅនឹង ឧទាហរណ៍។

보기




1) 
벌레를 잡다



2) 
물을 주다



3) 
거름을 주다



4) 
씨앗을 뿌리다



정답 1) 벌레를 잡아야 하는데요. 지금 할 수 있어요? 2) 물을 줘야 하는데요. 지금 할 수 있어요?
3) 거름을 줘야 하는데요. 지금 할 수 있어요? 4) 씨앗을 뿌려야 하는데요. 지금 할 수 있어요?

## 정보 ព័ត៌មាន

# 한국 농촌의 사계절

រដូវកាលទាំងបួននៃជនបទ(ស្រុកស្រែចម្ការ)ប្រទេសកូរ៉េ



### 봄 រដូវផ្ការីក

농사를 지을 준비를 합니다. 비료를 뿌리고 밭을 갈아 씨를 뿌리거나 모종을 심을 준비를 합니다. 토마토, 가지, 오이, 호박, 고추 등을 심습니다.

ជាពេលត្រៀមខ្លួនក្នុងការធ្វើកសិកម្ម។ ត្រៀមក្នុងការដាំកូនឈើ ឬធ្វើការបាចជី(កសិកម្ម) ភ្ជួរដី និងធ្វើការដាំគ្រាប់ពូជ ឬសំណាប។ ធ្វើការដាំបន្លែដូចជាផ្លែប៉េងប៉ោះ ត្រប់ ត្រសក់ ល្ពៅ ក៏ដូចជាម្ទេសជាដើម។



### 여름 រដូវក្ដៅ

봄에 심은 채소 등을 수확합니다. 논에 농약을 뿌리고 잡초를 뽑는 작업을 계속 해야 합니다. 밭에 당근, 양파, 파 등을 심고 키웁니다. 또한 겨울철 김장에 필요한 배추도 심습니다.

គឺជាពេលប្រមូលផលបន្លែដែលបានដាំនៅរដូវផ្ការីក(និទាឃរដូវ)។ ហើយក៏ជាពេលត្រូវធ្វើការបាញ់ថ្នាំសម្លាប់សត្វល្អិតនៅតាមវាលស្រែហើយនិងបន្តការងារដកស្មៅ។ ធ្វើការដាំការ៉ុត ខ្ទឹមបារាំង និងស្លឹកខ្ទឹមជាដើមនៅលើដី។ ហើយក៏ធ្វើការដាំស្ពៃបូកគោសម្រាប់ធ្វើគីមឈី នារដូវរងាផងដែរ។

### 가을 រដូវស្លឹកឈើជ្រុះ

가을은 수확의 계절입니다. 여름철에 잘 키운 채소와 벼를 거둡니다.

រដូវស្លឹកឈើជ្រុះ គឺជារដូវប្រមូលផល។ គឺធ្វើការប្រមូលផលបន្លែ និងស្រូវដែលដាំដុះបានយ៉ាងល្អនារដូវក្ដៅ។





### 겨울 រដូវរងា

1년 동안 사용한 농기구를 수리하고 다음 해 농사를 계획합니다. 겨울에도 비닐하우스에서 여러 가지 채소와 과일을 재배합니다.

ធ្វើការជួសជុលឧបករណ៍កសិកម្មដែលប្រើរយៈពេលមួយឆ្នាំ ដើម្បីគ្រោងក្នុងការទុកប្រើប្រាស់បន្តនៅឆ្នាំក្រោយទៀត។ សូម្បីតែក្នុងរដូវរងាក៏គេធ្វើការដាំបន្លែ និងផ្លែឈើនៅក្នុងរោងដាំដំណាំគ្របប្លាស្ទិក(រោងផ្ទះកញ្ចក់ដាំបន្លែ)ជាច្រើនប្រភេទដែរ។



សំណួរទី១និងទី២គឺជាការមើលរូបភាព បន្ទាប់មកជ្រើសរើសចម្លើយដែលត្រឹមត្រូវ។
មុនពេលស្ដាប់ សូមមើលរូបភាពឲ្យបានច្បាស់ជាមុនសិន។

[1~2] 다음 그림을 보고 알맞은 대답을 고르십시오.
ចូរមើលរូបភាពខាងក្រោម បន្ទាប់មកចូរជ្រើសរើសយកចម្លើយដែលត្រឹមត្រូវ។

Track 141

1. 이것은 무엇입니까? តើនេះគឺជាអ្វី?



① ② ③ ④

2. 이 사람은 무엇을 합니까? តើមនុស្សម្នាក់នេះ កំពុងតែធ្វើអ្វី?



① ② ③ ④



សំណួរទី៣ គឺជាការស្ដាប់ការសន្ទនា បន្ទាប់មកជ្រើសរើសចម្លើយដែលត្រឹមត្រូវទៅនឹងសំណួរ។
ចំណែកឯសំណួរទី៤និងទី៥វិញ តាមរយៈការស្ដាប់ការសន្ទនាតែមួយគត់ បន្ទាប់មកជ្រើសរើសចម្លើយ
ដែលត្រឹមត្រូវទៅនឹងសំណួរ។ មុននឹងស្ដាប់ សូមមើលរូបភាពនិងខ្លឹមសារនៃចម្លើយឲ្យបានច្បាស់ជាមុនសិន។

3. 이야기를 듣고 질문에 알맞은 대답을 고르십시오.
សូមស្ដាប់ការសន្ទនា បន្ទាប់មកចូរជ្រើសរើសយកចម្លើយដែលត្រឹមត្រូវទៅនឹងសំណួរ។

여자는 이제 무엇을 할 것입니까? តើមនុស្សស្រី ពេលនេះនឹងធ្វើសកម្មភាពអ្វី?

① 밭에 물을 줄 것입니다. ② 잡초를 뽑을 것입니다.
③ 호스를 가지고 올 것입니다. ④ 아주머니를 기다릴 것입니다.

[4~5] 하나의 이야기를 듣고 두 개의 질문에 대답하십시오.
សូមស្ដាប់ការនិយាយតែមួយគត់ បន្ទាប់មកចូរឆ្លើយនឹងសំណួរទាំងពីរ។

4. 내일 남자가 작업해야 하는 장소는 어디입니까? តើថ្ងៃស្អែក ទីកន្លែងដែលមនុស្សប្រុសត្រូវបំពេញការងារនៅឯណាដែរ?

① 논 ② 밭 ③ 논과 밭 ④ 과수원

5. 내일 해야 할 작업이 아닌 것은 무엇입니까? តើការងារដែលមិនមែនជាការងារដែលត្រូវបំពេញនៅថ្ងៃស្អែក គឺជាការងារអ្វី?

① 
② 
③ 
④ 



## 듣기 대본 អត្ថបទនៅក្នុងវិញ្ញាសាស្តាប់

1. ① 여: 경운기입니다. គឺជាម៉ាស៊ីនកិនស្រូវ។ ② 여: 손수레입니다. គឺជារទេះរុញ។
   ③ 여: 콤바인입니다. គឺជាម៉ាស៊ីនច្រូត និងបែន។ ④ 여: 트랙터입니다. គឺជាត្រាក់ទ័រ។
2. ① 남: 거름을 주고 있습니다. កំពុងតែធ្វើការដាក់ជី។
   ② 남: 농약을 치고 있습니다. កំពុងតែធ្វើការបាញ់ថ្នាំសម្លាប់សត្វល្អិត។
   ③ 남: 모종을 심고 있습니다. កំពុងតែធ្វើការដាំកូនឈើ។
   ④ 남: 벌레를 잡고 있습니다. កំពុងតែធ្វើការចាប់សត្វល្អិត។
3. 여: 밭에 물을 좀 줘야 하는데요. 창고에 호스가 없네요.
   ខ្ញុំ(គិតថា)គួរតែស្រោចទឹកនៅចម្ការ។ អូ! នៅឃ្លាំង មិនមានទុយោទេ។
   남: 아, 조금 전에 아주머니가 과수원에 물을 주려고 가지고 갔어요.
   អា! មុននេះបន្តិច អ្នកមីងគាត់បានយកទៅ ដើម្បីស្រោចទឹកនៅចម្ការផ្លែឈើហើយ។
   여: 그래요? 그럼, 물 주기 전에 밭에 잡초 좀 뽑을게요.
   អញ្ចឹងរឺ? បើអញ្ចឹង មុនពេលស្រោចទឹក ចាំខ្ញុំទៅដកស្មៅនៅឯចម្ការ។

4–5. 남: 내일은 무슨 일을 해야 해요? តើថ្ងៃស្អែក ត្រូវធ្វើការងារអ្វីដែរ?
   여: 논에 농약을 좀 쳐 주세요. សូមធ្វើការបាញ់ថ្នាំសម្លាប់សត្វល្អិតនៅឯស្រែផង។
   남: 네, 그럴게요. 그건 오전에 끝낼 수 있을 거 같은데, 오후에는 고구마 밭에 가서 거름을 좀 줄까요?
   បាទ, ចាំខ្ញុំធ្វើ។ តែការងារនេះដូចជាអាចបញ្ចប់នៅពេលព្រឹកបាន បើអញ្ចឹងតើពេលរសៀលគួរតែទៅចម្ការដាក់ជីដំឡូងខ្លះផងយ៉ាងម៉េចដែរ?
   여: 며칠 전에 줬으니까 거름은 안 줘도 되고요, 대신 물을 좀 주세요. 그리고 요새 벌레가 많아진 거 같은데 벌레도 좀 잡아 주고요.
   ដោយសារតែកាលពីប៉ុន្មានថ្ងៃមុន ទើបតែដាក់ដែរ អញ្ចឹងឥឡូវមិនទាន់ថែមក៏បាន តែជំនួសឲ្យការដាក់ជី សូមអ្នកស្រោចទឹកបន្ថែមបន្តិចផង។ ហើយមួយរយៈនេះ ដូចជាមានសត្វល្អិតកើនឡើងច្រើន អញ្ចឹងសូមជួយចាប់សត្វល្អិតឲ្យផង។

정답 1. ③ 2. ③ 3. ② 4. ③ 5. ②

## 확장 연습 លំហាត់អនុវត្តបន្ថែម

L-45

1. 다음을 듣고 이어지는 말로 알맞은 것을 고르십시오.
   សូមស្តាប់ បន្ទាប់មកចូរជ្រើសរើសយកពាក្យសម្តីដែលត្រូវភ្ជាប់ឲ្យបានត្រឹមត្រូវ។
   ① 고구마를 많이 심었어요. ② 어제 줬으니까 괜찮아요.
   ③ 고구마를 심도록 하세요. ④ 어제 거름을 많이 샀어요.

### 확장 연습 듣기 대본 អត្ថបទស្តាប់នៅក្នុងលំហាត់អនុវត្តបន្ថែម

1. 남: 고구마 밭에 거름을 좀 줄까요? តោះ! ធ្វើការដាក់ជីនៅចម្ការដំឡូងយ៉ាងម៉េចដែរ?

정답 1. ②

# EPS-TOPIK 읽기 វិញ្ញាសាអាន EPS-TOPIK



សំណួរទី១និងទី២ គឺជាការមើលរូបភាព បន្ទាប់មកជ្រើសរើសប្រយោគដែលត្រឹមត្រូវ ។ សូមរំលឹកពីអ្វីដែលអ្នកបានរៀនរួចមកហើយនោះបណ្តើរ និងធ្វើការឆ្លើយសំណួរបណ្តើរ។

[1~2] 다음 그림을 보고 맞는 단어나 문장을 고르십시오.

ចូរមើលរូបភាពខាងក្រោម ហើយធ្វើការជ្រើសរើសពាក្យ ឬប្រយោគដែលត្រឹមត្រូវ។

1. 

① 낫　② 삽
③ 괭이　④ 호미

2. 

① 땅을 파고 있습니다.　② 물을 주고 있습니다.
③ 고구마를 캐고 있습니다.　④ 물건을 운반하고 있습니다.



សំណួរទី៣និងសំណួរទី៤ គឺជាការជ្រើសរើសពាក្យដែលត្រឹមត្រូវដើម្បីបំពេញការសន្ទនា។
ចំណែកឯសំណួរទី៥វិញ គឺជាការអានអត្ថបទ បន្ទាប់មកជ្រើសរើសចម្លើយដែលត្រឹមត្រូវទៅនឹងសំណួរ។
សូមសាកល្បងគិតពីពាក្យនិងវេយ្យាករណ៍ដែលបានរៀនរួចមកហើយនោះបណ្តើរ និងសាកល្បងឆ្លើយសំណួរបណ្តើរ។

[3~4] 빈칸에 들어갈 가장 알맞은 것을 고르십시오.

ចូរជ្រើសរើសចម្លើយដែលត្រឹមត្រូវជាងគេក្នុងការបំពេញចន្លោះ។

3.
가: 이 파종상자를 어디에 둘까요? តើគួរដាក់ប្រអប់សាបព្រួសនេះនៅកន្លែងណា?
나: 밭으로 가져갈 거니까 ____________에 실어 놓으세요.
ចាំខ្ញុំយកវាទៅចម្ការ ដូច្នេះសូមដាក់វាក្នុងគោយន្តទៅ។

① 호스　② 갈고리　③ 경운기　④ 물뿌리개

4.
가: 모종을 심기 전에 밭에 비료를 ____________ 돼요.
មុនពេលដាំកូនឈើ ត្រូវធ្វើការបាចជីគីមីនៅចម្ការជាមុនសិន។
나: 네, 알겠습니다. បាទ/ចាស ខ្ញុំយល់ហើយ។

① 캐야　② 따야　③ 심어야　④ 뿌려야



5. 다음 질문에 답하십시오. ចូរធ្វើការឆ្លើយសំណួរខាងក្រោម។

토마토는 보통 4월 말에 밭에 모종을 심습니다. 모종을 심기 전에 밭에 비료를 뿌리고 일주일 정도 기다린 후 모종을 심어야 합니다. 모종을 심고 난 후에는 물을 주고 거름도 줍니다. 토마토는 벌레가 많이 생기는 작물이라서 가끔 농약을 쳐야 합니다. 또 잡초가 생기면 잡초를 뽑아서 토마토가 잘 자랄 수 있게 해야 합니다.
ផ្លែប៉េងប៉ោះ ជាធម្មតាគេដាក់ដាំកូនប៉េងប៉ោះលើថ្នាលចម្ការនាចុងខែមេសា។ មុននឹងដាក់ដាំកូនប៉េងប៉ោះ គេបាញ់ថ្នាំបំប៉នលើថ្នាលចម្ការទុកជាមុន រួចហើយក្រោយពីរង់ចាំបានប្រហែលជាមួយអាទិត្យ ទើបបានដាក់កូនប៉េងប៉ោះដាំ។ ក្រោយពីដាំកូនប៉េងប៉ោះរួចមក គេស្រោចទឹកនិងដាក់ជីធម្មជាតិ។ ផ្លែប៉េងប៉ោះគឺជាដំណាំដែលមានកើតសត្វល្អិតច្រើន ហេតុនេះហើយគេបាញ់ថ្នាំគីមីយូរៗម្តង។ បន្ថែមលើនេះទៅទៀត ប្រសិនបើស្មៅដុះ គេបោចស្មៅចេញ ត្រូវតែធ្វើដូចនេះទើបផ្លែប៉េងប៉ោះអាចលូតលាស់បានយ៉ាងល្អ។

토마토를 심을 때 가장 먼저 해야 하는 일은 무엇입니까?
នៅពេលដាំផ្លែប៉េងបោះ តើអ្វីដែលយើងត្រូវធ្វើមុនគេ?

① 거름을 줍니다. ② 모종을 심습니다.
③ 비료를 뿌립니다. ④ 잡초를 뽑습니다.

정답 1. ① 2. ① 3. ③ 4. ④ 5. ③

## 확장 연습 លំហាត់អនុវត្តបន្ថែម

[1~3] 빈칸에 들어갈 가장 알맞은 것을 고르십시오. ចូរជ្រើសរើសយកចម្លើយដែលត្រឹមត្រូវបំផុតមកបំពេញចន្លោះ។

1. 고향에 계신 어머니께 드리려고 옷을 샀습니다. 내일은 우체국에 가서 그 옷을 어머니께 ________로 보내려고 합니다.
ខ្ញុំបានទិញសម្លៀកបំពាក់ដើម្បីជូនអ្នកម្តាយដែលនៅឯស្រុកកំណើត។ ថ្ងៃស្អែកខ្ញុំមានបំណងទៅប្រៃសណីយ៍ដើម្បីផ្ញើសម្លៀកបំពាក់នោះជូនអ្នកម្តាយ។

① 우표 ② 편지 ③ 소포 ④ 엽서

2. 저는 버스로 회사에 다니는데 ________ 시간에는 차가 많이 막힙니다. 그래서 내일부터는 지하철로 다니려고 합니다.
ជាធម្មតាខ្ញុំធ្វើដំណើរទៅក្រុមហ៊ុនដោយជិះឡានក្រុង តែនៅម៉ោងចេញនិងចូលធ្វើការឡានស្ទះខ្លាំងណាស់។ ដូច្នេះហើយចាប់ពីស្អែកទៅ ខ្ញុំមានបំណងចង់ជិះរថភ្លើងក្រោមដីធ្វើដំណើរវិញ។

① 방문 ② 교육 ③ 출퇴근 ④ 환송회

3. 저는 회사 ________에서 살고 있습니다. 많은 사람들이 함께 생활하기 때문에 규칙을 잘 지켜야 합니다.
ខ្ញុំកំពុងស្នាក់នៅក្រុមហ៊ុន។ ដោយសារត្រូវរស់នៅជាមួយនិងមនុស្សច្រើន ដូច្នេះខ្ញុំត្រូវគោរពទៅតាមក្បួនច្បាប់ឲ្យបានខ្ជាប់ខ្ជួន។

① 기숙사 ② 자료실 ③ 상담센터 ④ 고용센터

정답 1. ③ 2. ③ 3. ①